ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ថ្នាលគ្រឹះឌីជីថលកម្ពុជា"

ស្របតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩, វិស័យឌីជីថលបានបញ្ជាបខ្លួនយ៉ាងជ្រៅក្នុងការប្រាស្រ័យទាក់ទងគ្នា, ការអនុវត្តការងារនិងមុខរបរ និងការរស់នៅប្រចាំថ្ងៃ រួមទាំងទិដ្ឋភាពនានានៃសកម្មភាពសង្គម និងសេដ្ឋកិច្ច ។ ជាក់ស្តែង, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ដែលជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអភិវឌ្ឍថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដែលថ្នាលនេះត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីពាក់កណ្តាលឆ្នាំ ២០២០ កន្លងទៅ ស្របពេលនៃការដាក់ដំណើរការជាផ្លូវការនូវថ្នាលចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងថ្នាល CamDigiKey ។ គោលបំណងនៃថ្នាល CamDX គឺសម្រាប់ប្រើប្រាស់ក្នុងការផ្លាស់ប្តូរទិន្នន័យពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៀត សំដៅសម្រួលដល់ការបំពេញការងារប្រកបដោយប្រសិទ្ធភាពរបស់មន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសម្រួលដល់សាធារណៈជនដែលប្រើប្រាស់ប្រព័ន្ធ ជាមួយនិងការចំណេញពេលវេលា និងថវិកា ។ ទន្ទឹមនេះ, ថ្នាល CamDigiKey ក៏ត្រូវបានអភិវឌ្ឍ និងយកមកប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណរបស់អ្នកប្រើប្រាស់ មុនពេលចូលទៅកាន់ផតថលនៃសេវាសាធារណៈផ្សេងៗ របស់រាជរដ្ឋាភិបាល ដែលបានភ្ជាប់មកថ្នាល CamDX ។ ដោយឡែក, បច្ចេកវិទ្យាហត្ថលេខាឌីជីថល (Digital Signature) ក៏បាននិងកំពុងប្រើប្រាស់ផងដែរ ក្នុងប្រតិបត្តិការលើថ្នាល CamDX និង CamDigiKey សម្រាប់ផ្ទៀងផ្ទាត់ភាពពិតប្រាកដនៃប្រតិបត្តិការឌីជីថល ឬឯកសារឌីជីថលផ្សេងៗ និងមានតម្លៃស្មើនឹងហត្ថលេខាដែលសរសេរដោយដៃ ឬ បោះត្រា ដែលផ្តល់នូវសុវត្ថិភាពច្រើនជាងមុន ។ ក្រុមការងារបច្ចេកទេសមជ្ឈមណ្ឌលបណ្តុះធុរកិច្ច "តេជោ" បាននិងកំពុងអភិវឌ្ឍ និងកំពុងធ្វើតេស្តសាកល្បង ការរួមបញ្ចូលនូវបច្ចេកវិទ្យានេះទៅក្នុងប្រព័ន្ធនានាផ្សេងទៀត សម្រាប់ដាក់ដំណើរការក្នុងប្រព័ន្ធអេកូឡូស៊ី CamDX ផងដែរ ។ ដូច្នេះ, បច្ចេកវិទ្យាទាំង ៣ នេះ សុទ្ធតែមានសារៈសំខាន់ខ្ពស់ ក្នុងការជំរុញការធ្វើបរិវត្តកម្មឌីជីថល ស្របតាមទិសដៅក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា។

ដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង ក៏ដូចជាការប្រើប្រាស់ថ្នាល CamDX, ថ្នាល CamDigiKey និង បច្ចេកវិទ្យាហត្ថលេខាឌីជីថល (Digital Signature) ក្នុងវិស័យសាធារណៈ, នារសៀលថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០២២, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និង មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយមួយស្តីពី "ថ្នាលគ្រឹះឌីជីថលកម្ពុជា" នៅសណ្ឋាគារភ្នំពេញ (Phnom Penh Hotel) ។ សិក្ខាសាលានេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការនៃ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និង មន្ត្រីរាជការពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សរុបប្រមាណ ១២០ រូប ។

**ឯកឧត្តមបណ្ឌិត គង់ ម៉ារី** បានអញ្ជើញថ្លែងសុន្ទរកថាគន្លឹះ ដោយបានគូសរំលេចអំពីសារៈ-សំខាន់ អត្ថប្រយោជន៍ និងនិរន្តភាពនៃថ្នាលគ្រឹះឌីជីថលសំខាន់ទាំង៣ ដែលស្របទៅនឹងគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលឱ្យកាន់តែទូលំទូលាយ ដើម្បីផ្តល់កំណើនដល់សេដ្ឋកិច្ចជាតិ និងផ្តល់សេវាសាធារណៈកាន់តែប្រសើរ ប្រកបដោយប្រសិទ្ធភាព ។ នៅក្នុងសិក្ខាសាលានេះ, ប្រធានបទសំខាន់ទាំង៣ ត្រូវបានលើកយកមកធ្វើបទបង្ហាញដោយវាគ្មិនកិត្តិយស រួមមាន **លោក យិន កក់ផឹង** អំពីថ្នាល CamDX, **លោក ទិត្យ ដារ៉ាយ៉ុង** អំពីថ្នាល CamDigiKey និង **លោក ប៉េង ឆ័យឡេង** អំពីហត្ថលេខាឌីជីថល ដោយមានការចូលរួមយ៉ាងផុលផុស ក្នុងវេទិកាសំណួរ-ចម្លើយ រវាងវាគ្មិនកិត្តិយស និងអ្នកចូលរួម ផងដែរ បន្ទាប់ពីការធ្វើបទបង្ហាញអំពីប្រធានបទនីមួយៗ ។

សូមគូសបញ្ជាក់ដែរថា ក្នុងរយៈពេល ២ឆ្នាំ កន្លងទៅ, ថ្នាល CamDX បានពង្រីកវិសាលភាពប្រើប្រាស់ទៅកាន់សេវាសាធារណៈដូចជា ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានដំណាក់កាលទី១ និង ដំណាក់-កាលទី២, ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស(GTAS), ប្រព័ន្ធស្នើសុំលិខិតបញ្ជាក់លើការធានាអញ្ជើញ សម្រាប់វិនិយោគិនដែលធ្វើដំណើរចូលមកប្រទេសកម្ពុជាក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ (ត្រូវបានផ្អាកដំណើរការរួចទៅហើយដោយសារស្ថានភាពប្រសើរឡើងនៃជំងឺកូវីដ-១៩) និង ប្រព័ន្ធសម្គាល់អត្ត-សញ្ញាណអតិថិជនឌីជីថល (e-KYC) ។ ក្នុងពេលឆាប់ៗខាងមុខ, ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី៣ ក៏នឹងត្រូវផ្លាស់ប្តូរទិន្នន័យតាមថ្នាល CamDX នេះដែរ ។ បច្ចុប្បន្ន, ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជាមានសមាជិកចំនួន ៩ រួមមាន៖ ក្រសួងមហាផ្ទៃ, ក្រសួងពាណិជ្ជកម្ម, អគ្គនាយកដ្ឋានពន្ធដារ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេក-វិទ្យា និង នវានុវត្តន៍, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនិយ័តករអាជីវកម្មអចលន-វត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ គិតត្រឹមថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២២ ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជាមានប្រតិបត្តិការសរុបចំនួន **៩,៦០៦,១៣១** ដែលក្នុងនោះ ប្រតិបត្តិការសរុបនៃថ្នាលចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មានចំនួន **៩ ២៣០ ២៥៧** រីឯ APIs មានចំនួនសរុប **២១៣** ។

បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តឱ្យគ្រប់ក្រសួង-ស្ថាប័ន ដែលចូលរួមជាមួយថ្នាល CamDX ប្រើប្រាស់ថ្នាល CamDigiKey ជាដំណោះស្រាយពេញលេញ ឬហៅថា Full Solution ដោយមានទាំងការផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកប្រើប្រាស់ពេលចូលទៅប្រើប្រាស់ប្រព័ន្ធ និងការបើក APIs ផងដែរ ជាមួយនឹងព័ត៌មានបុគ្គលដែលមានបំពេញនៅក្នុងពាក្យស្នើសុំ ថាជាមនុស្សតែមួយ ឬមនុស្ស ២នាក់ផ្សេងគ្នា ជៀសវាងការក្លែងបន្លំ និងផ្តល់ព័ត៌មានមិនពិត ។ CamDigiKey ក៏ជាប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (e-KYC) ផ្តោតលើភាពងាយស្រួល និង សុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ ។ ប្រព័ន្ធនេះតម្រូវឱ្យអ្នកប្រើប្រាស់គ្រាន់តែចុះឈ្មោះតែមួយដងជាមួយនឹងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែនសម្រាប់ជនបរទេស។ គិតត្រឹមថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២២, ចំនួនសរុបនៃអ្នកប្រើប្រាស់ ឬអ្នកមានគណនី CamDigiKey មានចំនួន **៧,០៦៦** ។